

១២-០៥-២០១៣

# ព្រះសង្ឃនិងសង្គម

## →ដោយព្រះមហាភិរម្យ←

**ព្រះសង្ឃ** បានដល់  ក្រុមអ្នកបួសចាប់ពី ៤ រូបជាដើមទៅ មានត្រឹមតែ៣ឬ២ រូបហៅថា **គណៈ** បើមានត្រឹមតែ ១ រូប ហៅថា **បុគ្គល** ។ **អ្នកបួស** បានដល់ អ្នកវៀរបង់ចាកការមានផ្ទះសម្បែងមកជាការគ្មានផ្ទះសម្បែង ដែលហៅម៉្យាងទៀត ថា **បព្វជិត** បុរសណា ៗឲ្យតែមានអាយុគ្រប់ ២០ ឆ្នាំឡើងទៅហើយ មានសទ្ធាត្រូវការបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនានេះអាចសម្រេចបិត្តបានក្រោមលក្ខខណ្ឌថា

1. ជាសុភាពបុរសដែលមានកិរិយាប្រព្រឹត្តត្រឹមត្រូវ មិនប្រព្រឹត្តអនាចារ ដូចជា សេពគ្រឿងញៀន ឬ គ្រឿងស្រវឹងជាដើម ទាំងមិនមានរោគឆ្លង ដូចជា រោគឃ្លង់ស្ពៅ ឬ រោគអេដស៍ជាដើម
2. ជាអ្នកមានចំណេះចេះអាននិងសរសេរអក្សរបាន ។
3. មាតាបិតាអនុញ្ញាត ។
4. មានអាយុគ្រប់ ២០ ឆ្នាំ ។

5. មិនមែនជាអ្នកមានទិដ្ឋិវិបត្តិ ឬជាមិច្ឆាទិដ្ឋិកបុគ្គល ។

6. មិនមានទោសទណ្ឌខាងរាជការ ។

7. មិនមែនជាបុគ្គលរលំរលាយ ពោលគឺ មិនមានបំណុលពាក់ព័ន្ធ ។

8. ជាអ្នកប្រាសចាកបព្វជ្ជាទោស និងមានរាងកាយមាំមួន អាចបំពេញសមណកិច្ចបាន មិនមែនជាជនចាស់ជរា ឬ ជនពិការជាដើម ។

9. មានសមណៈបរិក្ខារគ្រប់និងត្រឹមត្រូវតាមព្រះវិន័យ ។

10. ជាអ្នកអាចពោលពាក្យសូមបព្វជ្ជានិងឧបសម្បទាបានដោយខ្លួនឯង មិនមានអក្ខរវិបត្តិ ។

មានគុណសម្បត្តិគ្រប់ទាំង ១០ ប្រការទើបអាចបួសជាបព្វជិតបាន ។

អ្នកដែលត្រូវការបួសជាសាមណេរហៅថា **បព្វជ្ជាបេក្ខៈ** កំណត់អាយុតាំងពី ៧ ឆ្នាំដល់ ១៩ ឆ្នាំ ។

អ្នកដែលត្រូវការបួសជាភិក្ខុ ហៅថា **ឧបសម្បទាបេក្ខៈ** កំណត់អាយុតាំងពី ២០ ឆ្នាំ ដល់ ៦០ ឆ្នាំ ។

អ្នកដែលត្រូវការបួសជាភិក្ខុត្រូវចូលទៅរកព្រះឧបជ្ឈាយ៍ នៅពេលព្រះឧបជ្ឈាយ៍អនុញ្ញាតហើយ ព្រះឧបជ្ឈាយ៍ត្រូវនាំទៅទទួលឧបសម្បទានៅចំពោះមុខជំនុំសង្ឃ បន្ទាប់ពីនោះ ជំនុំសង្ឃបានចាត់ឲ្យភិក្ខុ ២ រូបគឺ **អនុសាវនាចារ្យ** និង **កម្មវាចាចារ្យ** ជាតំណាងសួរដេញដោលគុណសម្បត្តិឧបសម្បទាបេក្ខៈនោះនៅចំពោះមុខសង្ឃ ហើយលើកស្នើញត្តិ ១ ដង ឲ្យជំនុំសង្ឃសម្រេច បើជំនុំសង្ឃមិនជំទាស់ទេ ទើបសូធ្យអនុសាវនា ៣ ដងទៀត ទើបសម្រេចជាភិក្ខុបរិបូរណ៍ក្នុងព្រះពុទ្ធសាសនា ។ ហៅការបួសដោយស្នើញត្តិ ១ ដង និង សូធ្យអនុសាវនា ៣ ដង នៅចំពោះមុខជំនុំសង្ឃថា **ញត្តិចតុត្ថកម្ម** ។

ការបួសធ្វើក្នុងសីមាដែលសង្ឃ ១០ រូប ឬ ៥ រូបកំណត់ឡើងឬធ្វើក្នុងឧបោសថាគារ ប្រកបដោយព្រះឧបជ្ឈាយ៍ ១ រូប គូសូធ្យ ២ រូប គណៈបូរកៈដែលគង់ហត្ថបាស ២ ឬ ៣ រូប ឬច្រើនជាងនេះ ឧប សម្បទាបេក្ខៈ ១ រូប ឬ ២ រូប ញត្តិ ១ ដង និង អនុសាវនា ៣ ដង ។

ការបួសជាភិក្ខុក្នុងយុគសម័យបច្ចុប្បន្ននេះហៅថា **ញត្តិចតុត្ថកម្មឧបសម្បទា** ។

កន្លែងដែលបព្វជិតបួសហើយអាស្រ័យនៅ ហៅថា **វិហារ** ឬ ដែលយើងហៅថា **វត្ត** គឺ ទីកន្លែងសម្រាប់ហ្វឹកហាត់បរិយធម៌ ។

**វិហារ** ប្រែថា កន្លែងជាទីអាស្រ័យនៅរបស់អ្នកបួសទាំងឡាយ មានវិគ្គហៈថា **វិហរន្តិ ឯត្ថាតិ វិហារោ** អ្នកបួសទាំងឡាយអាស្រ័យនៅក្នុងកន្លែងនេះ ព្រោះហេតុនោះ កន្លែងនេះទើបឈ្មោះថា **វិហារ** គឺ វត្ត ។

អ្នកគ្រប់គ្រងវត្ត ហៅថា **វិហារាធិបតី** ឬដែលយើងហៅថា **ព្រះចៅអធិការ** ។

ក្រុមអ្នកបួសតាំងពី ៤ រូបឡើងទៅដែលអាស្រ័យនៅក្នុងវត្តដោយប្រើភាសាណាមួយជាយានដើម្បីទាក់ទងប្រាស្រ័យគ្នានិងប្រព្រឹត្តបដិបត្តិតាមគោលសាសនា ឬ បរិយធម៌ ឬ វប្បធម៌ដូចគ្នា ហៅថា **សង្គមសង្ឃ** ។

កិច្ចការដែលព្រះសង្ឃត្រូវធ្វើ គឺ

1. សិក្សាស្វែងរកចំណេះដឹងសាសនធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលយើងហៅថា សិក្សាផ្លូវធម៌(បឋមំ ពុទ្ធវចនំ) ។

2. សិក្សាស្វែងរកចំណេះដឹងបន្ថែមក្រៅពីសាសនធម៌ ដែលយើងហៅថា សិក្សាផ្លូវលោក (ទុតិយំ លោកកិច្ចំ) ។

3. សិក្សាស្វែងរកចំណេះដឹងផ្នែកវេជ្ជសាស្ត្រដើម្បីជួយគ្នានៅគ្រាមានអាពាធ ដែលយើងហៅថា រៀនពេទ្យ(តតិយំ វេជ្ជគន្ថំ) ។

4. សិក្សាជំនាញផ្នែកសិប្បកម្មដែលអាចចូលរួមជួយសង្គមបាន ដែលយើងហៅថា រៀនជាង បិត្រកម្ម ឬ វិស្វកម្ម (បតុត្ថំ សិប្បកម្មំ) ។

5. លះបង់អំពើអាក្រក់គ្រប់ប្រភេទ (សព្វបាបស្ស អករណំ ឬ បហាន)។

6. សិក្សាឈ្វេងយល់ទាំងផ្លូវលោកនិងផ្លូវធម៌ឲ្យបានច្បាស់លាស់(សច្ឆិកិរិយា) ។

7. អភិវឌ្ឍឬធ្វើឲ្យបម្រើនទាំងផ្នែកនាមធម៌និងរូបធម៌(ភាវនា) ។

អ្នកដឹកនាំបាត់ជារឿងសំខាន់ ស្ងួម្បីតែវត្តអារាមក៏ត្រូវមានអ្នកដឹកនាំដែរ ដែលយើងហៅថា មេវត្ត ឬ ចៅអាវាស ឬ ព្រះចៅអធិការ ហេតុនោះ វត្តទើបក្លាយជាសភាររបស់ប្រជាជន ពោលគឺ

1. វត្តជាទីស្នាក់អាស្រ័យរបស់ភិក្ខុសាមណេរ
2. វត្តជាទីបួសរៀនរបស់កូនចៅអ្នកស្រុក
3. វត្តជាទីរួបរួមក្បួនច្បាប់បុរាណ
4. វត្តជាទីអនុរក្សនិងអភិវឌ្ឍវប្បធម៌អរិយធម៌
5. វត្តជាទីធ្វើបុណ្យកុសលរបស់អ្នកស្រុកបំណុះជើងវត្ត
6. វត្តនិងព្រះសង្ឃជាទីពឹងផ្លូវចិត្តរបស់ប្រជាជន
7. វត្តជាមជ្ឈមណ្ឌលសកម្មភាពរបស់សង្គមនិងប្រជាជន
8. វត្តជាទីបណ្ដុះសីលធម៌បរិយធម៌របស់ប្រជាជន
9. វត្តជាទីជួបជុំរបស់ប្រជាជន
10. វត្តជាទីអភ័យទានរបស់មនុស្សនិងសត្វ

វត្តមានវេវចនសព្ទ ២ ទៀតដែលគួរឈ្វេងយល់ដែរ គឺ អារាម និង អាវាស

**អារាម** ប្រែថា កន្លែងជាទីធ្វើដំណើរមកហើយរីករាយសប្បាយចិត្ត មានវិគ្គហៈថា **អាគន្ត្វា រមន្តិ ឯត្ថាតិ អារាមោ** ប្រែថា ជនទាំងឡាយមកហើយតែងរីករាយសប្បាយចិត្តក្នុងកន្លែងនេះ ព្រោះហេតុនោះ កន្លែងនេះទើបឈ្មោះថា **អារាម** ជាទីមកហើយរីករាយសប្បាយចិត្ត ។

**អាវាស** ប្រែថា កន្លែងជាទីមកហើយរស់នៅ សំដៅយកតែបព្វជិតដែលបួសហើយក្នុងទីដទៃធ្វើដំណើរមករស់នៅក្នុងកន្លែងនេះបាន មានវិគ្គហៈថា **អាគន្ត្វា វសន្តិ ឯត្ថាតិ អាវាសោ** បព្វជិតទាំងឡាយមកហើយរស់នៅក្នុងកន្លែងនេះ ព្រោះហេតុនោះ កន្លែងនេះទើបឈ្មោះថា **អាវាស**ជាទីមកហើយរស់នៅ ។

ហេតុនោះ ពាក្យថា វត្តមានវេវចនសព្ទដល់ទៅ ៣ គឺ វិហារ អារាម និង អាវាស ។

កន្លែងជាទីស្នាក់អាស្រ័យរបស់បព្វជិត គឺ **វិហារ** និង **អាវាស** ឯកន្លែងជាទីមកទស្សនកិច្ចរបស់មហាជន គឺ **អារាម** ឃើញថា នៅពេលយើងនិយាយថា **វត្តអារាម** សំដៅដល់ ទាំងកន្លែងរស់នៅរបស់បព្វជិតទាំងកន្លែងមកលំហែចិត្តរបស់មហាជន ហេតុនោះវត្តអារាមទើបជាទីទេសចរណ៍របស់មនុស្សទូទៅ ព្រះសង្ឃនិងគ្រាមវាសី គឺ ប្រជាជនត្រូវអាស្រ័យគ្នាទៅវិញទៅមក វត្តអារាមទើបជាគោលដៅនៃសកម្មភាពរបស់មនុស្សគ្រប់ស្រទាប់វណ្ណៈ ការគ្រប់គ្រងវត្តអារាមទើបប្រព្រឹត្តទៅដើម្បីផលប្រយោជន៍របស់សង្គម ពោលគឺ ត្រូវប្រកបដោយគោលបំណង ៣ យ៉ាង គឺ

1. គ្រប់គ្រងវត្តអារាមឲ្យមានរបៀបរៀបរយ ។
2. បាត់របៀបទីធ្លាវត្តអារាមឲ្យត្រឈឹងត្រឈៃ ។
3. បាត់កម្មវិធីណាមួយត្រូពិបារណាដល់សង្គមនិងប្រជាជន ។

ការដែលនឹងទៅដល់គោលបំណងទាំង ៣ ប្រការនោះបាន អ្នកគ្រប់គ្រងវត្ត ត្រូវគ្រប់គ្រងនិងត្រួតត្រាគោលការណ៍ ៨ បំណុចដូចតទៅនេះឲ្យបានប្រិតប្រៀង

1. ត្រួតត្រាព្រះសង្ឃក្នុងអាវាសឲ្យមានរបៀបវិន័យ ។
2. ធ្វើនិងប្រើឲ្យធ្វើសមណធម៌ ដូចជា ចុះធ្វើឧបោសថកម្មរាល់កន្លះខែ បិណ្ឌបាត នមស្ការព្រះរតនត្រ័យនៅពេលព្រឹក ឬ ល្ងាច បោសប្រាស់ទីធ្លាវត្ត រក្សាសំពត់គ្រង នៅបរិវាសកម្ម បម្រើនព្រះកេសាកោរពុកមាត់ពុកចង្កា កាត់ក្រចក សិក្សាសិក្ខាបទ បដិបត្តិព្រះឧបជ្ឈាយ៍ វិទ្យាចារ្យ ទេសនាបត្តិ និងពិចារណាបច្ចវេក្ខណៈទាំង ៤ ជាដើម ។
3. សេនាសនៈ គឺ ទីស្នាក់អាស្រ័យរបស់ភិក្ខុសាមណេរឲ្យស្អាតបាត
4. សុខមាលភាព គឺ អតិរេកបច្ច័យសម្រាប់មើលថែសុខភាពរបស់ភិក្ខុសាមណេរ ។
5. សម្បត្តិវត្ត គឺ ផលប្រយោជន៍ឬចំណូលរបស់វត្ត ។
6. សប្បុរស គឺ ទាយកដែលទំនុកបម្រុងវត្ត ។
7. សង្ឃាធិការ គឺ ទំនាក់ទំនងជាមួយនឹងស្ថាប័នគ្រប់គ្រងសង្ឃ ។
8. សាធារណសង្គ្រោះ គឺ បំពេញប្រយោជន៍សង្គម ។

ព្រះសង្ឃគឺជាអ្នកដែលរស់នៅកៀកនឹងប្រជាជន និងអាស្រ័យប្រជាជនរស់នៅ ត្រូវអប់រំបណ្តុះបណ្តាលជួយសង្គមដូចតទៅនេះ

1. លើកស្ទួយសីលធម៌ បរិយធម៌ និង វប្បធម៌
2. អប់រំសុខភាពអនាម័យតាមដែលអាចធ្វើបាន
3. លើកស្ទួយសម្មាជីព គឺ មុខរបរស្របច្បាប់និងត្រឹមត្រូវតាមសីលធម៌
4. លើកស្ទួយសន្តិភាពនិងសន្តិសុខសង្គម
5. សិក្សាសង្គ្រោះ គឺ សិក្សាប្រៀបធៀបរវាងផ្លូវធម៌និងផ្លូវលោក
6. សាធារណសង្គ្រោះ គឺ បំពេញប្រយោជន៍សង្គមតាមដែលអាចធ្វើបាន
7. លើកស្ទួយកតញ្ញូកតវេទិតាធម៌ក្នុងបំណោមប្រជាជន
8. លើកស្ទួយសាមគ្គីធម៌ក្នុងបំណោមប្រជាជន

ព្រះសង្ឃទើបក្លាយជាអ្នកដឹកនាំចិត្តវិញ្ញាណរបស់ប្រជាជនដែលពួកគាត់តែងពោលថា **សង្ឃំ សរណំ គច្ឆាមិ** គឺ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ។